ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ២១០៣/២៤ មស.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារសម្រាប់គម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- បានឃើញសេចក្តីសម្រេចលេខ ៣១ សសរ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ
- យោងតាមការចាំបាច់



ផ្លូវវិថីអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមការងារដឹកនាំ និងគ្រប់គ្រងគម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| . ឯកឧត្តម | **យក់ ម៉ុនណា** | រដ្ឋលេខាធិការប្រចាំការនៃក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល | ប្រធានគម្រោង |
| . ឯកឧត្តម | **ឆាយ ឆត្រាវុធ** | រដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ | អនុប្រធានគម្រោង |
| . ឯកឧត្តម | **ឈុន សុជាតិ** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ក.ស. | សមាជិក |
| . ឯកឧត្តម | **ប្រាក់ ម៉ូវ** | អគ្គនាយកនៃក្រសួងមុខងារសាធារណៈ | សមាជិក |
| . ឯកឧត្តម | **ជា ឡាលីន** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គ.ក.ស. | សមាជិក |
| . ឯកឧត្តម | **សៀត វិចិត្រ** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គ.ក.ស. | សមាជិក |

ក្រុមការងារដឹកនាំ និងគ្រប់គ្រងគម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងចាត់ចែងគម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣
- សម្រេចលើផែនការសម្រាប់ចុះសិក្សា និងប្រមូលទិន្នន័យពាក់ព័ន្ធនឹងការអនុវត្តជោគជ័យរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣
- សម្របសម្រួលនិងតាមដានដំណើរការនៃការរៀបចំ ការចុះប្រមូលទិន្នន័យ និងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣
- ណែនាំ និងផ្តល់អនុសាសន៍ដល់ក្រុមការងារ សម្រាប់រៀបចំករណីសិក្សាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣ ឱ្យទទួលបានលទ្ធផលតាមការគ្រោងទុក
- ពិនិត្យ និងសម្រេចលើករណីសិក្សាជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣
- ផ្តល់របាយការណ៍ជូនគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ អំពីវឌ្ឍនភាពនៃអនុវត្តគម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣
- រៀបចំបោះពុម្ព និងផ្សព្វផ្សាយសៀវភៅនិងវីដេអូករណីសិក្សាដល់បណ្តាអង្គភាពផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំ វិស័យសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ។

**ប្រការ២**.-

បង្កើតក្រុមការងាររៀបចំចងក្រងករណីសិក្សាស្ដីពីការគ្រប់គ្រងនិងការផ្ដល់សេវាសាធារណៈរបស់ជ័យលាភី អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣ ដែលមានសមាសភាពដូចខាងក្រោម៖

**១. ក្រុមការងាររៀបចំករណីសិក្សាស្ដីពីការគ្រប់គ្រងនិងការផ្ដល់សេវាសាធារណៈរបស់សាលាបឋមសិក្សា សម្ដេច ជា ស៊ីម ខេត្តបាត់ដំបង**

- ឯកឧត្តមបណ្ឌិត **ជ័យ សារិន** អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា ប្រធាន
- ឯកឧត្តម **សូលី ចណ្ណាប៉ុក** នាយករងនៃសាលាភូមិន្ទរដ្ឋបាល អនុប្រធាន
- ឯកឧត្តម **យន ម៉ាលីមឆេង** ទីប្រឹក្សានៃ អ.គ.ហ. នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **ប្រាក់ ប្រានីដ្ឋា** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គ.ក.ស. សមាជិក
- លោក **ជ័យ រតនា** អនុប្រធានលេខាធិការដ្ឋាននៃអគ្គាធិការដ្ឋាននៃ ក្រសួងអប់រំ យុវជននិងកីឡា សមាជិក
- លោក **គួច ថុន** អនុប្រធាននាយកដ្ឋាននៃក្រសួងមហាផ្ទៃ សមាជិក
- លោក **ស្រី ម៉ារ៉ូណា** អនុប្រធាននាយកដ្ឋាននៃក្រសួងបរិស្ថាន សមាជិក
- លោក **ប៉ូល អមិតអិត្យា** ប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ សមាជិក

**២. ក្រុមការងាររៀបចំករណីសិក្សាស្ដីពីការគ្រប់គ្រងនិងការផ្ដល់សេវាសាធារណៈរបស់សាលាបឋមសិក្សាស្វាយជ្រំ ខេត្តស្វាយរៀង**

- លោកជំទាវ **នាង លីណា** អនុរដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ ប្រធាន
- លោកបណ្ឌិត **ភាន់ ពុទ្ធី** អនុប្រធាននាយកដ្ឋាននៃក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន
- លោកបណ្ឌិត **ណុច រ៉ាម៉ូ** ប្រធានលេខាធិការដ្ឋាននៃសាលាភូមិន្ទរដ្ឋបាល សមាជិក
- លោកស្រី **ហាច តីរម្យ** អនុប្រធាននាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ សមាជិក
- លោក **ម៉ុន ហៃ** អនុប្រធានការិយាល័យនៃក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ សមាជិក
- លោក **ហ៊ី ឌីណារ៉ាត្ន** ប្រធាននាយកដ្ឋាននៃទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក
- លោកស្រី **យក់ សុគន្ធា** អនុប្រធាននាយកដ្ឋាននៃសាលាភូមិន្ទរដ្ឋបាល សមាជិក
- លោក **ម៉ុនថន ម៉ុនឆៃ** ប្រធានការិយាល័យនៃអគ្គលេខាធិការដ្ឋាន គ.ក.ស. សមាជិក
- លោក **តាំង គីមម៉េង** មន្ត្រីនៃក្រសួងបរិស្ថាន សមាជិក

៣. ក្រុមការងាររៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់អនុវិទ្យាល័យភ្នំយ៉ាត ខេត្តប៉ៃលិន

- ឯកឧត្តមបណ្ឌិត **អ៊ុន ស៊ីវុធថា** អនុរដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ ប្រធាន
- លោក **ព្រីង មរកត** ប្រធាននាយកដ្ឋាននៃក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន
- លោក **យ៉ែម មករា** មន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- លោក **លន គឹមហេង** អគ្គនាយករងនៃក្រសួងមុខងារសាធារណៈ សមាជិក
- លោក **អ៊ូច សោភ័ណ** មន្ត្រីជំនាញជាន់ខ្ពស់នៃ អ.គ.ហ. សមាជិក
- លោក **ជា ម៉េង** ប្រធានការិយាល័យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- កញ្ញា **ស៊ីង លក្ខណា** មន្ត្រីនៃក្រសួងបរិស្ថាន
- លោក **គឹមបូរ វ៉ាណូ** មន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- កញ្ញា **ឡុង សុផានីម** មន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- កញ្ញា **មុំ មរកត** មន្ត្រីនៃក្រសួងមុខងារសាធារណៈ សមាជិក

៤.ក្រុមការងាររៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់មណ្ឌលសុខភាពសំពោង ខេត្តពោធិ៍សាត់

- ឯកឧត្តមបណ្ឌិត **សយ រាសី** អគ្គាធិការនៃក្រសួងមុខងារសាធារណៈ ប្រធាន
- លោកវេជ្ជបណ្ឌិត **លី វិជ្ជាវ៉ាន់ធុច** ប្រធាននាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាល អនុប្រធាន
- លោកស្រីវេជ្ជបណ្ឌិត **លឹម ខាន់ត្រីភា** អនុប្រធានការិយាល័យធានាគុណភាពសុខាភិបាលនៃក្រសួងសុខាភិបាល សមាជិក
- លោក **រាត់ ស៊ិទ្ធ** អគ្គនាយករងនៃក្រសួងបរិស្ថាន សមាជិក
- លោក **ប៊ុន ម៉ានិត** អនុប្រធានអង្គភាពនៃ គ.ជ.អ.ប. សមាជិក
- លោក **ជា ផល្លី** ប្រធាននាយកដ្ឋាននៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- លោកស្រី **អ៊ិត ផល្លីស** ប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ សមាជិក
- លោក **ញ៉ែម វិច្ឆិកា** ប្រធាននាយកដ្ឋាននៃសាលាភូមិន្ទរដ្ឋបាល សមាជិក
- លោក **ហេង សុជាតិ** ប្រធានការិយាល័យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- លោកស្រី **អ៊ុំ វលក្ខទេវី** មន្ត្រីជំនាញនៃ អ.គ.ហ. សមាជិក

ក្រុមការងាររៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣ ខាងលើ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការលម្អិតនិងឯកសារពាក់ព័ន្ធសម្រាប់ចុះសិក្សា ប្រមូលទិន្នន័យ និងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់សាលារៀនឬមណ្ឌលសុខភាពគោលដៅ ដើម្បីសុំការសម្រេចពីក្រុមការងារដឹកនាំនិងគ្រប់គ្រងគម្រោង
- សហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការរៀបចំករណីសិក្សា
- ចុះសិក្សានិងប្រមូលទិន្នន័យដល់ទីតាំងសាលារៀនឬមណ្ឌលសុខភាពគោលដៅ និងភាគីពាក់ព័ន្ធ
- រៀបចំសេចក្តីព្រាងករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់សាលារៀន និងមណ្ឌលសុខភាពជាគោលដៅ និងស្នើសុំការសម្រេចជាចុងក្រោយពីក្រុមការងារដឹកនាំនិងគ្រប់គ្រងគម្រោង
- បំពេញការងារចាំបាច់នានា តាមការណែនាំពីប្រធានក្រុមការងារដឹកនាំនិងគ្រប់គ្រងគម្រោង។

**ប្រការ៣.-**

បង្កើតក្រុមការងាររៀបចំវីដេអូករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣ ទាំង៤ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| - ឯកឧត្តម | **ទិត ច័ន្ទតារា** | ទីប្រឹក្សាបច្ចេកទេស ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | ប្រធាន |
| - លោកស្រី | **ដារ៉េត រ៉ូហ្សាលីន** | នាយិការងខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| - លោក | **ពេជ្រ និពន្ធ** | ប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| - លោក | **ម៉ែន សំណាង** | អនុប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ | សមាជិក |
| - លោក | **លាន សុខា** | អនុប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ | សមាជិក |
| - លោក | **ឈឿន វណ្ណឌី** | អនុប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ | សមាជិក |
| - លោកស្រី | **យុទ្ធ ស្រីរ័ត្ន** | មន្ត្រីនៃខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | សមាជិក |
| - លោក | **ហ៊ុយ ឧស្សាហ៍** | មន្ត្រីនៃក្រសួងមុខងារសាធារណៈ | សមាជិក |
| - លោក | **ហ៊ី ឆាយ** | មន្ត្រីនៃក្រសួងមុខងារសាធារណៈ | សមាជិក |
| - លោក | **គួយ ឡុង់ឌី** | មន្ត្រីនៃក្រសួងមុខងារសាធារណៈ | សមាជិក |

ក្រុមការងាររៀបចំវីដេអូករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣ ទាំង៤ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- រៀបចំផែនការលម្អិតនិងឯកសារពាក់ព័ន្ធសម្រាប់ចុះប្រមូលទិន្នន័យ និងថតវីដេអូករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់សាលារៀនឬមណ្ឌលសុខភាពគោលដៅ ដើម្បីសុំការសម្រេចពីក្រុមការងារដឹកនាំនិងគ្រប់គ្រងគម្រោង
- ចុះប្រមូលទិន្នន័យ និងថតវីដេអូនៅទីតាំងជាក់ស្តែងរបស់សាលារៀន មណ្ឌលសុខភាព និងភាគីពាក់ព័ន្ធ

- ○ រៀបចំសេចក្តីព្រាងវីដេអូករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់សាលារៀន និងមណ្ឌលសុខភាពជាគោលដៅ និងស្នើសុំការសម្រេចជាចុងក្រោយពីក្រុមការងារដឹកនាំនិងគ្រប់គ្រងគម្រោង
- ○ បំពេញការងារចាំបាច់នានា តាមការណែនាំពីប្រធានក្រុមការងារដឹកនាំនិងគ្រប់គ្រងគម្រោង។

**ប្រការ៤.-**

បង្កើតក្រុមការងាររដ្ឋបាលនិងលេខាធិការ សម្រាប់គម្រោងរៀបចំករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| - | លោកស្រី **ឈាង អូនថ៉ា** | អគ្គនាយករងនៃក្រសួងមុខងារសាធារណៈ | ប្រធាន |
| - | លោក **តាន់ បេងលាង** | អគ្គាធិការរងនៃក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| - | លោក **ឈឹន សាលីន** | អនុប្រធាននាយកដ្ឋាននៃក្រសួងមុខងារសាធារណៈ | សមាជិក |
| - | លោកស្រី **រឿង រ័ត្ននិមល** | អនុប្រធាននាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ក.ស. | សមាជិក |
| - | លោក **ទេ ចិត្រា** | ប្រធានការិយាល័យនៃក្រសួងមុខងារសាធារណៈ | សមាជិក |
| - | លោកស្រី **ពៅ ធីតា** | ប្រធានការិយាល័យនៃអគ្គលេខាធិការដ្ឋាន គ.ក.ស. | សមាជិក |
| - | លោក **សៀត ម៉ូលី** | ប្រធានការិយាល័យនៃក្រសួងមុខងារសាធារណៈ | សមាជិក |
| - | លោកស្រី **ហេង ធីតា** | អនុប្រធានការិយាល័យនៃក្រសួងមុខងារសាធារណៈ | សមាជិក |

ក្រុមការងាររដ្ឋបាលនិងលេខាធិការ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ○ ផ្តល់ការគាំទ្រ និងសេវារដ្ឋបាលដល់ក្រុមការងារដឹកនាំនិងគ្រប់គ្រង ក្រុមការងាររៀបចំចងក្រងករណីសិក្សា និងក្រុមការងាររៀបចំវីដេអូករណីសិក្សា
- ○ ទំនាក់ទំនង និងសម្របសម្រួលជាមួយអង្គភាពផ្តល់សេវាសាធារណៈគំរូ ចំណាត់ថ្នាក់លេខ១ ឆ្នាំ ២០២៣ ដើម្បីរៀបចំចុះប្រមូលព័ត៌មាន និងទិន្នន័យដល់ទីតាំងអង្គភាពជាក់ស្តែង
- ○ រៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំពិភាក្សាលើការអនុវត្តគម្រោងរៀបចំករណីកសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣
- ○ រៀបចំឯកសារ និងនីតិវិធីរដ្ឋបាលសម្រាប់ដំណើរការចុះបេសកកម្ម ការចំណាយ និងការទូទាត់ដល់ក្រុមការងារអនុវត្តគម្រោង
- ○ បំពេញការងារផ្សេងទៀតទៅតាមការចាំបាច់។

**ប្រការ៥.-**

សមាសភាពក្រុមការងារ ដូចមានចែងក្នុងប្រការ១ ប្រការ២ និងប្រការ៣ នៃសេចក្តីសម្រេចនេះ ត្រូវទទួលបាន៖

- ប្រាក់បេសកកម្មសម្រាប់ការចុះសិក្សា ការប្រមូលព័ត៌មាននិងទិន្នន័យដល់ទីតាំងអង្គភាពជាក់ស្តែង
- ប្រាក់ឧបត្ថម្ភស្មើ ៨ ម៉ោងបង្រៀននៃសាស្ត្រាចារ្យរបស់សាលាភូមិន្ទរដ្ឋបាលក្នុងមួយថ្ងៃ ក្នុងការរៀបចំចងក្រងសៀវភៅនិងវីដេអូខ្លីករណីសិក្សាស្តីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣។

សមាសភាពក្រុមការងារដូចមានចែងក្នុងប្រការ៤ ត្រូវទទួលបាន៖

- ប្រាក់បេសកកម្ម សម្រាប់ការងារសម្របសម្រួលលើការចុះសិក្សា ការប្រមូលព័ត៌មាននិងទិន្នន័យដល់ទីតាំងអង្គភាពជាក់ស្តែង
- ប្រាក់កម្រៃឧបត្ថម្ភស្មើ ៤ ម៉ោងបង្រៀននៃសាស្ត្រាចារ្យរបស់សាលាភូមិន្ទរដ្ឋបាលក្នុងមួយថ្ងៃសម្រាប់ការងារសម្របសម្រួលជូនក្រុមការងាររៀបចំសរសេរករណីសិក្សាស្ដីពីការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ចំណាត់ថ្នាក់លេខ១ ឆ្នាំ២០២៣។

ក្រុមការងារ ត្រូវរៀបចំផែនការថវិកា និងអនុវត្តថវិកាសម្រាប់ដំណើរការរៀបចំករណីសិក្សារបស់ក្រុមការងារនីមួយៗ ស្របតាមគម្រោងថវិកាដែលមាននៅក្នុងផែនការថវិកាសម្រាប់ការអនុវត្តដំណើរការនៃការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល សម្រាប់ឆ្នាំ២០២៤។

**ប្រការ៦.-**

សមាសភាពក្រុមការងារ ដូចមានចែងក្នុងប្រការ១ ប្រការ២ ប្រការ៣ និងប្រការ៤ ខាងលើត្រូវគោរពនិងអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ច័ន្ទ ៣ រោច ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាប្រធាន គ.ថ.ជ.**

**ហ៊ុន ម៉ានី**

ចម្លងជូនៈ

- ខុទ្ទកាល័យសម្តេចមហាបវរធិបតី
- សមាជិកគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ